**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

## សេចក្តីជូនដំណឹង
## ស្តីពីការបែងចែកភាគលាភជូនភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
## របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន **ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី** ("**ក្រុមហ៊ុន**") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនទាំងអស់ មេត្តាជ្រាបថា ៖ ក្រុមហ៊ុននឹងបែងចែកភាគលាភជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ប្រភេទភាគលាភដែលបែងចែក | : | ជាសាច់ប្រាក់ |
| ២-រយៈពេលភាគលាភ | : | ប្រចាំឆ្នាំ២០២០ |
| ៣-អនុបាតនៃការបែងចែកភាគលាភ | : | ៥០,១០% នៃចំណេញក្រោយបង់ពន្ធប្រចាំឆ្នាំ២០២០ |
| ៤-ភាគលាភសរុបដែលបែងចែក | : | ៦០០.០០០.០០០ រៀល |
| ៥-ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | : | ១៥ រៀល |
| ៦-កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ | : | ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ |
| ៧-កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ | : | ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ |

បញ្ជាក់៖

១- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភ ដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការ ដែលទទួលបានពីបញ្ជីភាគហ៊ុនិកបណ្តោះអាសន្ន ដែលបានរៀបចំឡើងនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១។

២- ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ នៅតែមានសិទ្ធិទទួលបាននូវភាគលាភដដែល។

៣- ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១នឹងមិនមានសិទ្ធិទទួលបាន ភាគលាភ ដូចបានកំណត់ខាងលើនោះទេ។

៤- ការទូទាត់ភាគលាភ ចាប់ផ្តើមពីថ្ងៃទី១៤ ដល់ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ នៅរៀងរាល់ថ្ងៃធ្វើការ។ ក្នុងករណីមានភាពមិនត្រឹមត្រូវក្នុងការទូទាត់ភាគលាភខាងលើ ភាគហ៊ុនិកអាចធ្វើការតវ៉ាចាប់ពីថ្ងៃទី២១ ដល់ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ នៅរៀងរាល់ថ្ងៃធ្វើការ។

ព័ត៌មានបន្ថែមសូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ជំនួស របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដូចខាងក្រោម ៖

- អាសយដ្ឋាន : អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥)២៣-៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧)
- ទូរសារ: (៨៥៥)១៥ ៦០០ ៧៤៣
- ទូរស័ព្ទដៃ: (៨៥៥)១៥-៦០០ ៧៤៣
- អ៊ីម៉ែល: lim.an@acledabank.com.kh

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**

GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA